ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ
THE STUDENT MOVEMENT FOR DEMOCRACY

លេខ៖០០១១/២០ ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០

**សូមគោរពជូន**
**លោក ង្វៀន ស្វួន ហ្វ៊ុក** (Nguyen Xuan Phuc)
**នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

***លោកនាយករដ្ឋមន្ត្រីជាទីគោរពរាប់អាន***

យើងខ្ញុំ **ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** បានតាមដានយ៉ាងយកចិត្តទុកដាក់ នូវសេចក្តីថ្លែងរបស់លោក **ង្វៀន ស្វួន ហ្វ៊ុក** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងនាមជាប្រធានប្តូរវេននៃសមាគមអាស៊ាន (ASEAN) ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៦ កាលពីថ្ងៃទី២៦ ខែមិថុនា ថ្មីៗនេះ។ លោកនាយករដ្ឋមន្ត្រី បានអះអាងថា ៖

***«សមាគមប្រទេសអាស៊ានតាមឃ្លាំមើល និងលើកស្ទួយការអនុវត្តដ៏តឹងរ៉ឹងនិងពេញលេញ តាមសេចក្តីប្រកាសនៃក្រមប្រតិបត្តិ (DOC) របស់ភាគីនានា ក្នុងតំបន់សមុទ្រចិនខាងត្បូង និងក៏កំពុងតែប្រឹងប្រែងធ្វើគ្រប់មធ្យោបាយ ដើម្បីបង្កើតក្រមសីលធម៌ប្រសិទ្ធមួយ (COC) ស្របតាមច្បាប់អន្តរជាតិ រួមមានអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីអំពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ (UNCLOS)»***។

សេចក្តីថ្លែងអះអាងរបស់លោកនាយករដ្ឋមន្ត្រី គឺជាការប្តេជ្ញាចិត្តរបស់វៀតណាម ដើម្បីដោះស្រាយជម្លោះសមុទ្រចិនខាងត្បូង ក្នុងចំណោមប្រទេសនានាក្នុងសមាគមនអាស៊ានជាមួយចិន ដោយឈរលើគោលការណ៍ និងយន្តការស្របតាមខ្លឹមសារច្បាប់អន្តរជាតិ។ ដោយសារកម្ពុជា និងវៀតណាម មានវិវាទព្រំដែនដ៏ស្មុគស្មាញច្រើនសតវត្សរ៍មកហើយ និងនៅតែបន្តមានវិបត្តិដ៏ចម្រូងចម្រាសលើបញ្ហាផ្លូវច្បាប់នោះ **ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ សូមរំឭកលោកនាយករដ្ឋមន្ត្រីថា យើងខ្ញុំក៏ទាមទារឲ្យភាគីវៀតណាមងាកមកដោះស្រាយទំនាស់ព្រំដែនជាមួយភាគីកម្ពុជា តាមច្បាប់អន្តរជាតិ**។

ក្នុងស្មារតីលើកកម្ពស់ការគោរពច្បាប់អន្តរជាតិតាមស្តង់ដាតែមួយ ដើម្បីដោះស្រាយជម្លោះព្រំដែនវៀតណាម-កម្ពុជា ប្រទេសវៀតណាមក៏ត្រូវគោរព និងអនុវត្តកាតព្វកិច្ចតាមច្បាប់អន្តរជាតិជាធរមាន ដូចខាងក្រោម៖

### ១- អនុសញ្ញានៃអង្គការសហប្រជាជាតិ ស្តីអំពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ (UNCLOS 1982)

អនុសញ្ញាស្តីអំពីច្បាប់សមុទ្រឆ្នាំ១៩៨២ ផ្នែក២ ជំពូក២ មាត្រា៣ ចែងថា *«រដ្ឋទាំងអស់មានសិទ្ធិបង្កើតប្រវែងនៃដែនសមុទ្ររបស់ខ្លួនរហូតដល់ដែនកំណត់មិនលើសពីចម្ងាយ* ***១២ ម៉ាយល៍ ឬស្មើ ២២,២២៤ គីឡូម៉ែត្រ (1 nautical miles=1,852 meters)*** *ដែលវាស់ពីខ្សែបន្ទាត់មូលដ្ឋានដែនកំណត់អនុលោម តាមអនុសញ្ញានេះ»*។

យោងតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីអំពីច្បាប់សមុទ្រឆ្នាំ១៩៨២នេះ និងតាមលក្ខខណ្ឌ ភូមិសាស្ត្រ **កោះត្រល់ (ដែលវៀតណាមហៅថា Phú Quốc) គឺជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា ពីព្រោះកោះត្រល់មានរយៈចម្ងាយត្រឹមតែ ១៥ គីឡូម៉ែត្រ ពីឆ្នេរសមុទ្រខេត្តកំពត ប្រទេសកម្ពុជា ក្នុងរង្វង់ដែន ២២,២២៤ គីឡូម៉ែត្រ ដែលកំណត់ដោយច្បាប់សមុទ្រ ប៉ុន្តែកោះត្រល់នេះ មានរយៈចម្ងាយរហូតដល់ ៤៥ គីឡូម៉ែត្រ ពីតំបន់ហាទៀង ខេត្តកៀនយ៉ាង ប្រទេសវៀតណាម ដែលស្ថិតនៅផ្ទៃខាងក្រៅរង្វង់ដែន ២២,២២៤ គីឡូម៉ែត្រ កំណត់ដោយច្បាប់សមុទ្រនេះ**។

### ២- កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១ (PPA 1991)

ឯកសារទី២ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ មាត្រា១ ចំណុច២-ឃ ចែងថា ***«បញ្ចប់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយ ដែលមិនស្របអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាន នៃដែនដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ខ្លួន»***។

សន្ធិសញ្ញា និងកិច្ចព្រមព្រៀងឆ្នាំ១៩៧៩ ១៩៨២ ១៩៨៣ និងឆ្នាំ១៩៨៥ រវាងវៀតណាម-កម្ពុជា ក្រោមស្ថានភាពដែលកម្ពុជាត្រួតត្រាដោយកងទ័ពវៀតណាម បានក្លាយជា**មោឃភាព**អស់ហើយ ដោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ប៉ុន្តែរដ្ឋាភិបាលវៀតណាម និងរដ្ឋាភិបាលកម្ពុជា នៅតែយកមកធ្វើជាមូលដ្ឋានដោះស្រាយជម្លោះព្រំដែន

វៀតណាម-កម្ពុជា។ រីឯសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ២០០៥ និងឆ្នាំ២០១៩ ដែលរដ្ឋាភិបាលកម្ពុជាសព្វថ្ងៃប្រើជាបង្អែកដែរនោះ ក៏មានខ្លឹមសារបំពានទាំងស្រុង លើកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍នេះដែរ។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ឆ្នាំ១៩៩១ គឺជាលិខិតូបករណ៍អន្តរជាតិ ឬមានតម្លៃជាច្បាប់អន្តរជាតិ ដែលប្រទេសហត្ថលេខីទាំងអស់ ត្រូវអនុវត្តឲ្យត្រូវខ្លឹមសារ ដោយការគោរពគ្នាជាចាំបាច់។ វៀតណាម និងសមាជិកនៃអាស៊ាន ភាគច្រើន គឺជាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍នេះ។

**៣- គោលការណ៍អាស៊ាន (ASEAN Principles)**

ធម្មនុញ្ញអាស៊ាន មាត្រា២ ចំណុច២ ចែងថា *«អាស៊ាន និងរដ្ឋសមាជិក ត្រូវអនុវត្តឲ្យសមស្របតាម គោលការណ៍៖*

*ក. គោរពឯករាជ្យភាព អធិបតេយ្យភាព សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិ នៃរដ្ឋសមាជិកអាស៊ានទាំងអស់។*

*ខ. ចូលរួមការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវរួមគ្នា ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់។*

*គ. បដិសេធនូវអំពើឈ្លានពាន និងការគំរាមកំហែង ឬការប្រើប្រាស់កំលាំង ឬសកម្មភាពទាំងឡាយណា ក្នុងលក្ខណៈដែលមិនសមស្របតាមច្បាប់អន្តរជាតិ។»*។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមអំពាវនាវលោកនាយករដ្ឋមន្ត្រី **ង្វៀន សួន ហ្វុក** ប្រមុខនៃរដ្ឋាភិបាលវៀតណាម ត្រូវគោរព និងអនុវត្តឲ្យបានម៉ឺងម៉ាត់ តាមខ្លឹមសារនៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រឆ្នាំ១៩៨២, កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងធម្មនុញ្ញអាស៊ាន ដោយឈរលើគោលការណ៍ និងយន្តការស្តង់ដាតែមួយចំពោះប្រជាជាតិទាំងអស់។ យើងខ្ញុំ ក៏ទាមទារឲ្យរដ្ឋាភិបាលវៀតណាម អនុវត្តករណីជម្លោះព្រំដែនវៀតណាម-កម្ពុជា ដូចលោកនាយករដ្ឋមន្ត្រី បានជម្រុញលក្ខខណ្ឌប្រតិបត្តិជាអន្តរជាតិ ជុំវិញជម្លោះសមុទ្រចិនខាងត្បូង ជាមួយភាគីពាក់ព័ន្ធផងដែរ។

សូមលោកនាយករដ្ឋមន្ត្រី ទទួលនូវការគោរពរាប់អានអំពីយើងខ្ញុំ។

**ប្រធានប្រតិបត្តិ**

**ទូច វិបុល**